# ចំណាប់អារម្មណ៍របស់ខ្ញុំក្រោយពីបានស្តាប់កម្មវិធីវិទ្យុសហគមន៍របស់

# មជ្ឈមណ្ឌលឯកសារកម្ពុជា

នាងខ្ញុំឈ្មោះ គយ សេងគា ជានិស្សិតឆ្នាំទី៣ ផ្នែកប្រវត្តិវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ សព្វថ្ងៃនាងខ្ញុំរស់នៅភូមិស្នោរ សង្កាត់ស្នោរ ខ័ណ្ឌពោធិសែនជ័យ ភ្នំពេញ។ ក្រោយពីបានស្តាប់ការចាក់ផ្សាយរបស់កម្មវិធីវិទ្យុសហគមន៍ ស្តីអំពីអំពើប្រល័យពូជសាសន៍ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម ធ្វើឲ្យខ្ញុំបានដឹងកាន់តែច្បាស់ងអំពីទុកវេទនា និងភាពអត់ឃ្លានរបស់ប្រជាជនខ្មែរ ជាពិសេសការបង្ខំឲ្យធ្វើការជាទម្ងន់ ដោយមិនឲ្យពេលវេលាឈប់សម្រាក។ នេះសបញ្ជាក់ថាមេដឹកនាំសម័យខ្មែរក្រហម មិនបានយកចិត្តទុកដាក់លើប្រជាជនទេ ថែមទាំងរំលោភលើសិទ្ធិការងាររបស់ប្រជាជន ដូចដែលមានចែងជាអន្តរជាតិអំពីសិទ្ធិការងារផងដែរ។ បើយោងតាមសំដីរបស់ លោក ផេង ប្រជាជនខ្មែរពិតជាបានធ្វើការជាទម្ងន់ ដោយក្នុងមួយថ្ងៃសិងតែធ្វើការ២៤ម៉ោង។ បើប្រជាជនម្នាក់ៗធ្វើការហត់នឿយយ៉ាងហ្នឹង លទ្ធផលដែលទទួលបានសមនិងអាចឲ្យប្រទេសខ្មែររីកចំរើនខ្លាំង។ នៅក្នុងសម័យខ្មែរក្រហម ខ្មែរក្រហមបានត្រឹមបន្សល់កេរ្តិ៍ឈ្មោះអាស្រូវ ដោយការកាប់សម្លាប់ជាតិសាសន៍ឯង និងបង្ខំឲ្យប្រជាជនធ្វើការដោយមិនឲ្យបរិភោគអាហារឲ្យបានគ្រប់គ្រាន់ និងខ្វះជីជាតិ។ បើយោងតាមទិន្នផលស្រូវ ដែលប្រជាជនធ្វើការដាំដុះ និងប្រមូលផលបានក្នុងសម័យខ្មែរក្រហម មិនសមឲ្យប្រជាជនខ្មែរខ្វះអាហារហូបចុក និងស្លាប់ដោយសារការអត់ឃ្លាននោះទេ។ បើយើងក្រលេកមើលនៅក្នុង ប្រវត្តិសាស្ត្រខ្មែរប្រជាជនខ្មែរធ្វើស្រែតាមបែបយថាផល ធ្វើបានពី១ទៅ២ដងក្នុង១ឆ្នាំ ហើយក៏ទទួលនូវការបំផ្លាញដោយសារសង្គ្រាម ប៉ុន្តែ ប្រជាជនខ្មែរមិនដែលស្លាប់ដោយការអត់អាហារឡើយ។ ចំណែកឯសម័យខ្មែរក្រហម ប្រជាជនបានខិតខំធ្វើស្រែចំការ២ទៅ៣ដងក្នុងមួយឆ្នាំ ហើយតាមរយៈផែនការណ៍៤ឆ្នាំ ផលិតផលស្រូវត្រូវប្រមូលឲ្យបាន៣តោនក្នុងមួយហិតាជាមធ្យម ចុះហេតុអ្វីបានជាប្រជាជនស្លាប់ និងរស់នៅដោយភាព

អត់ឃ្លានទៅវិញ? នេះប្រហែល ជាមេដឹកនាំរបស់ខ្មែរក្រហមទាំងនេះមិនបានគិតគូរដល់ផលវិបាក និងទុកវេទនារបស់ប្រជាជន ដែលបណ្តាលមកពីការធ្វើការហួសកម្លាំង លក្ខខណ្ឌរស់នៅមិនមានផាសុខភាព និងការទទួលទានអាហារមិនគ្រប់គ្រាន់ ជាពិសេសការឆ្លងជម្ងឺដោយគ្មានថ្នាំព្យាបាល ការផ្តល់ថ្នាំនិងវ៉ាក់សាំង និងការថែទាំអ្នកជម្ងឺឲ្យបានជិតដល់។ យើងដឹងថាមនុស្សម្នាក់ៗបើកាលណាខ្វះអាហារ ដែលមានជីវជាតិសម្រាប់ថែទាំរាងកាយ វាធ្វើឲ្យរាងកាយ និងប្រព័ន្ធភាពផ្សាំនៅក្នុងរាងកាយចុះទ្រុឌទ្រោម ហើយជម្ងឺផ្សេងនិងងាយស្រួលចូលមកបំផ្លាញសុខភាពរបស់មនុស្សណាស់។ មេដឹកនាំខ្មែរក្រហមបែរជាយល់ថា ប្រជាជនខ្ជិលធ្វើការងារវិញ ដូចនេះហើយ បានជានៅសម័យខ្មែរក្រហមមានមនុស្សប្រមាណជិត២លាននាក់បានស្លាប់ ដោយសារតែការធ្វើការងារជាទម្ងន់ ការបរិភោគមិនគ្រប់គ្រាន់ ភាពអត់ឃ្លាន កង្វះថ្នាំពេទ្យនិងពេទ្យព្យាបាលជម្ងឺ។ ប្រជាជនខ្មែរនៅទូទាំងប្រទេសមិនបានទទួលការយកចិត្តទុកដាក់ទាំងផ្លូវកាយទាំងផ្លូវចិត្ត។

ជាចុងក្រោយនាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានរៀបចំកម្មវិធីវិទ្យុសហគមន៍ ដែលបានចាក់ផ្សាយអំពី អំពើប្រល័យពូជសាសន៍ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម និងបានរាយការណ៍ប្រវត្តិសាស្រ្តដ៏ជូរចត់និងខ្មៅងងឹតមួយនេះ ដើម្បីឲ្យកូនចៅជំនាន់ក្រោយៗបានយល់អំពីទុកសោក ការនិរាស្រ្តព្រាត់ប្រាស់ ភាពអត់ឃ្លានរបស់ប្រជាជនខ្មែរ។ ក្នុងនាមខ្ញុំជានិស្សិតប្រវត្តិសាស្រ្ត នាងខ្ញុំសូមអំពាវនាវដល់ អ្នកដឹកនាំខ្មែរទាំងអស់យកចិត្តទុកដាក់ចំពោះការហូបចុក និងការស្នាក់នៅរបស់ប្រជាជន ជាពិសេសកុមារកំព្រា។ សូមឲ្យអ្នកដឹកនាំ និងកុលបុត្រកុលធីតាខ្មែរជំនាន់ក្រោយទាំងអស់ចងចាំនូវព្រឹត្តិការមួយនេះ ដើម្បីកុំឲ្យសង្គមខ្មែរដើរជាន់ដានប្រវត្តិសាស្រ្តខ្មៅងងឹតមួយនេះទៀត។